# បទវិភាគ៖ ភាពយន្តចិនពីររឿង Lost in the Stars (ចិន៖ 消失的她) និង No More Bets ( ចិន៖ 孤注一掷 ) កំពុងធ្វើឱ្យភ្ញៀវទេសចរជនជាតិចិនព្រួយបារម្ភពីសុវត្ថិភាពក្នុងតំបន់អាស៊ីអាគ្នេយ៍

*រៀបរៀងដោយ៖ លោក ប៉ាង វេតនា , បណ្ឌិត សុង ស៊ីណា, លោក ទេព វន្តា*

*និង បណ្ឌិត ជិន សុជាតិ, នៃវិទ្យាស្ថានសិក្សាចិននៃរាជបណ្ឌិត្យសភាកម្ពុជា*

*ក្នុងពេលថ្មីៗនេះ អ្នកទស្សនាខ្សែភាពយន្តចិនចំនួនពីររឿងគឺ* Lost in the Stars (*ចិន៖* 消失的她) *និង* No More Bets (*ចិន៖* 孤注一掷 ) *បានធ្វើឱ្យមានការរំជើបរំជួលដល់ភ្ញៀវទេសចរជនជាតិចិនដែលមានបំណងមកទស្សនានៅបណ្តាប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអគ្នេយ៍ ដោយសារតែរឿងទាំងពីរសុទ្ធតែបានបង្ហាញពីបទឧក្រិដ្ឋកម្មលើជនជាតិចិនក្នុងតំបន់នេះ។*

Lost in the Stars (*ចិន៖* 消失的她) *គឺជាភាពយន្តឧក្រិដ្ឋកម្មអាថ៌កំបាំងចិនឆ្នាំ២០២២ ដែលដឹកនាំដោយ* Cui Rui *និង* Liu Xiang ។ *រឿងនេះបានបង្ហាញប្រាប់ពីប្រពន្ធរបស់* He Fei Li Muzi *ដែលបានបាត់ខ្លួនយ៉ាងអាថ៌កំបាំងក្នុងដំណើរកម្សាន្តខួបអាពាហ៍ពិពាហ៍។ វាជាខ្សែភាពយន្តដែលនិយាយអំពីរឿងរ៉ាវនៃករណីដ៏រន្ធត់មួយ ហើយបន្ទាប់មកស្ត្រីដែលបាត់ខ្លួនចុងក្រោយត្រូវបានគេបាញ់សម្លាប់*[1]។

Global Times *បានរាយការណ៍នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៣នេះថា ភាពយន្តចិនថ្មីមួយទៀត គឺ* Lost in The Stars *គឺជាខ្សែភាពយន្តដែលរកចំណូលបានច្រើនជាងគេមួយដែរ កំពុងតាមពីក្រោយដោយ* No More Bets ។ *នៅលើគេហទំព័រដ៏ពេញនិយមមួយឈ្មោះ* Douban *អ្នកប្រើប្រាស់* Liuyisi *បាននិយាយថា* Lost in The Stars *ពិពណ៌នាអំពីស្ត្រីដែលបាត់ខ្លួនដែលចុងបញ្ចប់ត្រូវបានសម្លាប់នៅតំបន់អាស៊ីអាគ្នេយ៍* ។

---

[1] https://www.theguardian.com/film/2023/jul/11/lost-in-the-stars-review-chinese-doppelganger-twist-a-thon-is-too-fun-to-resist




ដោយឡែកភាពយន្ត រឿង No More Bets ដែលភាសាចិនសរសេរថា 孤注一掷 គឺជាភាពយន្តចិនបែបឧក្រិដ្ឋកម្ម ដែលបានរៀបរាប់ពីដំណើររឿងអំពីមនុស្សដែលត្រូវបានគេជួញដូរទៅបរទេស និងបង្ខំឱ្យបោកប្រាស់តាមអ៊ីនធឺណិត។ តួអង្គបុរសក្នុងរឿងនេះគឺ Pan Sheng គឺអ្នកសរសេរកម្មវិធីអនឡាញ និងតារាស្រីបង្ហាញម៉ូត Liang Anna ដែលត្រូវបានទាក់ទាញឱ្យទៅធ្វើការនៅឯ បរទេសដែលមានប្រាក់ខែខ្ពស់ ប៉ុន្តែចុងក្រោយក្លាយទៅជាទាសករចូលរួមប្រព្រឹត្តបទឧក្រិដ្ឋបោកប្រាស់តាមអនឡាញដោយបង្ខំក្នុងរោងចក្រក្លែងបន្លំមួយដែលមិនបានបញ្ជាក់ពីប្រទេសណាមួយឱ្យប្រាកដក្នុងតំបន់អាស៊ីអគ្នេយ៍ ប៉ុន្តែទិដ្ឋភាពក្នុងខ្សែភាពយន្តស្រដៀងនឹងប្រទេសថៃភាគច្រើន។ ដោយមិនចង់ឱ្យមានអ្នករងគ្រោះទៀត និងដើម្បីចង់ចាកចេញពីជំរំទាសករនោះ តួអង្គបានវាយប្រហារអ្នកលេងដែលជាក្រុមចាប់ពួកគេមកនោះ ហើយប្រមូលយកលុយក្រុមអ្នកលេង បន្ទាប់មកគេចខ្លួនពីអំពើឃោរឃៅ ប៉ុន្តែត្រូវប្រឈមនឹងការស៊ើបអង្កេតឆ្លងដែន រួមទាំងក្រុមប៉ូលីសក្នុងតំបន់ដែលមិនគួរឱ្យទុកចិត្ត។

ភាពយន្ត No More Bets នេះត្រូវបាននិពន្ធ និងដឹកនាំដោយ Shen Ao ។ នេះជាភាពយន្តទី ២ របស់គាត់ បន្ទាប់ពីរឿង My Dear Liar ក្នុងឆ្នាំ២០១៩ ហើយនៅឆ្នាំ២០២០ មិត្តភ័ក្តិម្នាក់បានប្រាប់គាត់ពីករណីធ្វើអត្តឃាតដោយសារការក្លែងបន្លំតាមអ៊ីនធឺណិត និងល្បែងស៊ីសង ។ បន្ទាប់មកអ្នកនិពន្ធ

លើកឡើងថា ដោយសំអាងលើករណីពិតរាប់ម៉ឺនករណី ទើបគាត់សម្រេចចិត្តថានឹងប្រែក្លាយបញ្ហានេះឱ្យទៅជាខ្សែភាពយន្តឧក្រិដ្ឋកម្ម។ មុនពេលថត ក្រុមការងារអ្នកដឹកនាំរឿង ដោយមានការគាំទ្រពីប៉ូលីស និងមជ្ឈមណ្ឌលប្រឆាំងការក្លែងបន្លំ បានប្រមូលករណីក្លែងបន្លំតាមអ៊ីនធឺណិតនៅក្រៅប្រទេសរាប់ម៉ឺនករណីត្រូវយកមកវិភាគ និងសំយោគ។ ការសរសេរស្គ្រីបសាច់រឿងចំណាយពេលមួយឆ្នាំកន្លះ។ ភាពយន្ត No More Bets ដែលមានរយៈពេល១៣០នាទី បានចាក់បញ្ចាំងជាលើកដំបូងនៅក្នុងប្រទេសចិននៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៣ ហើយគ្រាន់តែក្នុងមួយខែដំបូង ភាពយន្តនេះអាចស្វែងរកចំណូលបានរហូតដល់ជាង ៥០០លានដុល្លារ។




តាមរយៈរឿងទាំងពីរនេះធ្វើឱ្យអ្នកលេងក្នុងបណ្តាញសង្គមអនឡាញចិន កំពុងជជែកគ្នាថា តើអ្នកណាដែលនៅតែហ៊ានទៅតំបន់នេះ? ចំណែកប្រជាជន និងស្ថាប័នពាក់ព័ន្ធនៅក្នុងក្នុងតំបន់

នេះវិញ ដូចជាកម្ពុជា ថៃ មីយ៉ាន់ម៉ា ក៏កំពុងប្រតិកម្មលើរឿងទាំងនេះផងដែរថា វាបានធ្វើឱ្យខូចមុខមាត់ជាតិ[2]និងមានប៉ះពាល់ដល់វិស័យទេសចរណ៍។




ប្រទេសថៃពឹងផ្អែកយ៉ាងខ្លាំងលើវិស័យទេសចរណ៍ ជាពិសេសពីប្រទេសចិន។ ប្រទេសនេះបានស្វាគមន៍ភ្ញៀវទេសចរចិនច្រើនជាង ១០លាននាក់ជារៀងរាល់ឆ្នាំមុនពេលការរាតត្បាត Covid-១៩ ហើយខិតខំរកយុទ្ធសាស្ត្រដើម្បីឱ្យរឿងទាំងនេះវិលត្រឡប់ដូចដើមវិញ។ ស្ថានទូតថៃប្រចាំប្រទេសចិននៅក្នុងបទវិចារណកថាមួយកាលពីខែមីនា បន្ទាប់ពីស្ថានទូតបាននិយាយនៅលើវេទិកាមីក្រូប្លុក Weibo ថា "ប្រទេសថៃយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះគុណភាព និងសុវត្ថិភាពនៃការធ្វើដំណើររបស់អ្នកទេសចរចិន ក៏ដូចជាចំណាប់អារម្មណ៍វិជ្ជមានរបស់ពួកគេចំពោះប្រទេស"។ ជាលទ្ធផលពួកគេអាចទាញទេសចរណ៍ចិនចំនួនជាង ២លាននាក់ ហើយយុទ្ធនាការចុងក្រោយនេះនាយករដ្ឋមន្ត្រីថ្មីរបស់ប្រទេសថៃលោកស្រី Srettha Thavisin បាននិយាយនៅថ្ងៃទី២៥ ខែសីហា ថា ប្រទេសនេះនឹងមានវិធានការដើម្បីជំរុញចំនួនភ្ញៀវទេសចរចិន។ ការសន្យារបស់លោកបានធ្វើឡើងបន្ទាប់ពីប្រទេសថៃបានបន្ធូរបន្ថយការរឹតបន្តឹងទិដ្ឋាការសម្រាប់ជនជាតិចិនកាលពីថ្ងៃទី១១ ខែសីហា ដោយកាត់បន្ថយពេលវេលាដែលត្រូវការសម្រាប់ការអនុម័តទិដ្ឋាការ។ ប្រទេសចិនក៏ធ្លាប់ជាប្រកព

[2] ក្នុងសាច់រឿង ឈុតមួយតួអង្គធ្វើដំណើរពីស្រុកចិនចុះពីយន្តហោះមានឡានក្រុងមួយគ្រឿងដែលមានសរសេរអក្សរខ្មែរលើជញ្ជាំងរថយន្ត ដែលយើងអាចមើលឃើញខ្វះដែលសរសេរថា (យលឡុងគរុប) ប៉ុន្តែទិដ្ឋភាពនៃការថត ក្នុងភាពយន្តនេះគឺបានបន្តឆ្លងកាត់ថៃ ឡាវ និងមីយ៉ាន់ម៉ា(ព្រោះតាមដងផ្លូវក៏ឃើញមានអក្សរថៃ ឡាវ ហើយចុងក្រោយឃើញអក្សរមីយ៉ាន់ម៉ា មុនពេលរថយន្តនោះចូលទៅដល់ក្រុមហ៊ុនឆបោកមួយ។ ហេតុនេះក្រុមហ៊ុនរោងចក្រក្លែងបន្លំឆបោកមនុស្សតាមអ៊ីនធឺណិតក្នុងសាច់រឿងមិនបញ្ជាក់ឱ្យច្បាស់លាស់ថា នៅកន្លែងណាឱ្យប្រាកដទេក្នុងចំណោមប្រទេសទាំងបួននេះ ប៉ុន្តែឈុតមួយនៅលើអាវយឺតតួអង្គសម្តែងបានសរសេរអក្សរខ្មែរ។

ទេសចរណ៍ដ៏ធំបំផុតមួយរបស់ប្រទេសមីយ៉ាន់ម៉ាផងដែរ សូម្បីតែក្នុងអំឡុងពេលជំងឺរាតត្បាត និងសង្គ្រាមស៊ីវិលដែលកំពុងបន្តរបស់ប្រទេសក៏ដោយ។

នៅប្រទេសកម្ពុជាវិញ ក្នុងឆ្នាំ២០១៩ ភ្ញៀវបរទេសជាង ២.៣លាននាក់ក្នុងចំណោម ៦.៦លាននាក់មកទស្សនាកម្ពុជា ឬ៣៥% ជាជនជាតិចិន ដែលធ្វើឱ្យវាក្លាយជាទីផ្សារទេសចរណ៍ធំបំផុតរបស់កម្ពុជា។ នៅក្នុងការដេញថ្លៃដើម្បីទាក់ទាញភ្ញៀវទេសចរចិន បន្ទាប់ពីការដកបម្រាមទេសចរណ៍ជាក្រុមកាលពីខែមករា ឆ្នាំ២០២៣ ក្រសួងទេសចរណ៍កម្ពុជាបានចាប់ផ្តើមរៀបចំកម្មវិធីពិសេសមួយកាលពីដើមខែសីហា ដើម្បីផ្តល់ការទទួលស្គាល់ដល់ប្រតិបត្តិករអាជីវកម្មទេសចរណ៍ដែលគុណភាពសេវាកម្មស្របតាមស្តង់ដាររបស់ចិន។ ជាមួយនឹងគំនិតផ្តួចផ្តើម "China Ready" កម្ពុជាសង្ឃឹមថានឹងអាចទទួលបានភ្ញៀវទេសចរចិនយ៉ាងហោចណាស់ ៨០០ ០០០នាក់ នៅចុងឆ្នាំ២០២៣នេះ[3]។



https://www.postkhmer.com/business/2023-05-09-0746-249845.html

ប៉ុន្តែក្តីបារម្ភដែលបានបង្កឡើងដោយភាពយន្ត Lost in Stars និងជាពិសេសរឿង No More Bets ជាភាពយន្តបែបរន្ធត់ដែលមានកម្រិតខ្ពស់ដែលអ្នកនិពន្ធអះអាងថាផ្អែកលើ "ព្រឹត្តិការណ៍ពិត" ទើបនាំឱ្យមានការបង្កើតក្តីបារម្ភ។ យ៉ាងណាក៏ដោយនោះវាគ្រាន់តែជាខ្សែភាពយន្តប៉ុណ្ណោះ ហេតុអ្វីក៏ត្រូវមានក្តីបារម្ភ?

[3] https://www.japantimes.co.jp/news/2023/09/04/asia-pacific/crime-legal/china-cambodia-myanmar-tourism-cyberscams-trafficking/

បើតាមការសិក្សាលើករណីឧក្រិដ្ឋកម្មជាក់ស្តែងបង្ហាញថា នៅក្នុងប្រទេសចិន ការក្លែងបន្លំតាមអ៊ីនធឺណិតបានក្លាយជាបញ្ហាច្រើនក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ យោងតាមប្រព័ន្ធផ្សព្វផ្សាយរដ្ឋបានឱ្យដឹងថា គ្រាន់តែក្នុងឆ្នាំ២០២២ អាជ្ញាធរចិនបានរកឃើញករណីទូរគមនាគមន៍ និងការក្លែងបន្លំតាមអ៊ីនធឺណិតចំនួន ៤៦៤,០០០ករណី ដោយបានចាប់ខ្លួនមេដឹកនាំក្រុមក្មេងទំនើងចំនួន៣៥១ នាក់ និងសមាជិកសំខាន់ៗនៃក្រុមឧក្រិដ្ឋជន[4]។ ឧ.ករណីមួយកើតឡើងលើបុគ្គលអាយុ ៤៦ឆ្នាំម្នាក់ឈ្មោះ Xin Weilin ដែលជានាយកប្រតិបត្តិនៃក្រុមហ៊ុនទេសចរណ៍ដែលមានមូលដ្ឋាននៅទីក្រុង Guiyang ដែលបានរួចផុតមានសេរីភាពបន្ទាប់ពីត្រូវបានបង្ខំឱ្យធ្វើការឱ្យក្រុមបោកប្រាស់នៅក្នុងប្រទេសមីយ៉ាន់ម៉ា[5]។ នៅក្នុងឧបទ្ទវហេតុស្រដៀងគ្នានេះ បុគ្គលចំនួនប្រាំបីនាក់មកពីរដ្ឋ Sarawak ត្រូវបានបោកបញ្ឆោតដោយការបោកប្រាស់ការងារ ហើយត្រូវបានបង្ខំឱ្យក្លាយជាអ្នកបោកប្រាស់នៅក្នុងប្រទេសមីយ៉ាន់ម៉ា។ ដើមឡើយពួកគេត្រូវបានផ្តល់ការងារនៅក្នុងប្រទេសថៃតាមរយៈ Facebook ដោយសន្យាថានឹងទទួលបានប្រាក់ខែពី៣,០០០ ទៅ៦,០០០ RM (ប្រហែល១,២៧៥ដុល្លារអាមេរិក) ក្នុងមនុស្សម្នាក់។

ពលរដ្ឋចិនត្រូវបានស្ថានទូតចិនប្រចាំប្រទេសមីយ៉ាន់ម៉ា ក្រើនរំលឹកជាបន្តបន្ទាប់ ចាប់តាំងពីឆ្នាំមុន មិនឱ្យធ្វើតាមការប្រកាសការងារតាមអ៊ីនធឺណិតដែលមានប្រាក់ខែខ្ពស់ ឬចូលរួមក្នុងសកម្មភាពខុសច្បាប់។ នៅក្នុងសញ្ញានៃការកើនឡើងនៃកិច្ចសហប្រតិបត្តិការពហុជាតិលើបញ្ហានេះ ប្រទេសចិនបានសហការជាមួយមន្ត្រីសន្តិសុខសាធារណៈមកពីប្រទេសថៃ ឡាវ និងមីយ៉ាន់ម៉ា ដើម្បីរួមគ្នាបង្រ្កាបលើការក្លែងបន្លំតាមអ៊ីនធឺណិតដែលទាក់ទងនឹងការជួញដូរមនុស្សនិងឧក្រិដ្ឋកម្មល្បែងស៊ីសង[6]។

---

[4] https://www.japantimes.co.jp/news/2023/09/04/asia-pacific/crime-legal/china-cambodia-myanmar-tourism-cyberscams-trafficking/

[5] https://gutzy.asia/2023/09/27/chinese-tourists-avoid-myanmar-and-cambodia-amid-cyber-scams-and-human-trafficking-fears/

[6] https://www.japantimes.co.jp/news/2023/09/04/asia-pacific/crime-legal/china-cambodia-myanmar-tourism-cyberscams-trafficking/

ដោយឡែកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបាន ព្រមានថា និន្នាការនេះមិនរលាយបាត់ឡើយ ដោយយ៉ាងហោចណាស់មានមនុស្សចំនួន១២០,០០០ នាក់នៅក្នុងប្រទេសមីយ៉ាន់ម៉ា និងប្រហែល១០០,០០០នាក់នៅក្នុងប្រទេសកម្ពុជា អាចស្ថិតក្នុងស្ថានភាពដែលពួកគេត្រូវបង្ខំដោយក្រុមឧក្រិដ្ឋជនដើម្បីដឹកនាំការបោកប្រាស់តាមអ៊ីនធឺណិត។ ប្រទេសផ្សេងទៀតនៅក្នុងតំបន់រួមទាំងឡាវ ហ្វីលីពីន និងថៃ ក៏ត្រូវបានចាត់ទុកថាជាប្រទេសសំខាន់សម្រាប់ការឆ្លងកាត់ការជួញដូរមនុស្ស ឬជាគោលដៅរបស់ពួកគេសម្រាប់មនុស្សយ៉ាងហោចណាស់រាប់ម៉ឺននាក់[7]។ លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សលើកឡើងថា អ្វីដែលឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានលើកឡើងវាខុសពីចំនួនករណីដែលមានពិតនៅកម្ពុជា ពោលគឺបញ្ហាសរុបទាក់ទងនឹងជនជាតិចិននៅកម្ពុជា ដែលយើងបានស៊ើបអង្កេតកន្លងមកមានត្រឹមតែជាង១០០០ករណីប៉ុណ្ណោះ[8] ។

ករណីបទឧក្រិដ្ឋកម្មដែលជាពត៌មានពិត រួមទាំងភាពយន្តនេះហើយដែលនាំទៅដល់ការព្រួយបារម្ភ។ បើគេពិនិត្យមើលលើការស្ទង់ស្ទាបមតិវិញ បង្ហាញថា យុទ្ធនាការទាំងឡាយដើម្បីទាញទេសចរចិន កំពុងជួបបញ្ហាប្រឈម។ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ ការស្ទង់មតិនាពេលថ្មីៗនេះនៅលើ Weibo ដែលជាវេទិកា X-like របស់ប្រទេសចិន បានបង្ហាញថា អ្នកឆ្លើយសំណួរចំនួន ២៨,០០០ ក្នុងចំណោម៥២,០០០ នឹងជៀសវាងការធ្វើដំណើរទៅកាន់ប្រទេសមីយ៉ាន់ម៉ា ខណៈដែលប្រហែល៣,០០០ បាននិយាយថាពួកគេនឹងស្ទាក់ស្ទើរចំពោះដំណើរទេសចរណ៍បែបនេះដោយសារតែការព្រួយបារម្ភអំពីសុវត្ថិភាព។ នៅក្នុងការស្ទង់មតិមួយផ្សេងទៀតដែលសួរអ្នកប្រើប្រាស់អ៊ិនធឺណិតចិនថា តើពួកគេនឹងធ្វើដំណើរទៅកាន់អាស៊ីអាគ្នេយ៍ដែរឬទេ អ្នកឆ្លើយសំណួរជាង ៨៥% បាននិយាយថាទេ[9]។ អត្ថបទចចាមអារ៉ាមអនឡាញជាច្រើនចាប់ផ្តើមបំពងគួរឱ្យរន្ធត់ទាក់ទងនឹង 'ការ

[7] https://apnews.com/article/cambodia-myanmar-migrants-online-scams-ebab962f236df69b1f9b7e136958e244

[8] https://www.facebook.com/RFIKhmer/videos/1489598225212260/?extid=NS-UNK-UNK-UNK-AN_GK0T-GK1C&mibextid=6aamW6

[99] https://www.japantimes.co.jp/news/2023/09/04/asia-pacific/crime-legal/china-cambodia-myanmar-tourism-cyberscams-trafficking/

ជួញដូរស្រ្តី និង 'ការជេកក្រលៀន'[10]។ និស្សិតទីក្រុងប៉េកាំង Leanna Qian អាយុ២២ឆ្នាំបានប្រាប់ AFP ថាខណៈពេលដែលនាងដឹងថារឿងរ៉ាវមួយចំនួនត្រូវបាន"បំផ្លើស" តែនាងនៅតែមានការព្រួយបារម្ភអំពីការធ្វើដំណើរទៅកាន់អាស៊ីអគ្នេយ៍។ នាងបាននិយាយថា៖ «ខ្ញុំបារម្ភថាយើងនឹងត្រូវគេយកទៅកន្លែងផ្សេងទៀតដូចជាកម្ពុជា ឬមីយ៉ាន់ម៉ា»[11]។ ប៉ុន្តែអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមចិនជាច្រើនទៀតជឿថា អ្នកសរសេរប្លុកខ្លះកំពុងសរសេរបំផ្លើសដើម្បីទាក់ទាញការយកចិត្តទុកដាក់"។

លោក Sisdivachr Cheewarattanaporn ប្រធានសមាគមភ្នាក់ងារទេសចរណ៍ថៃបានប្រាប់ AFPថា ការជជែកតាមអ៊ីនធឺណិតបែបអវិជ្ជមានបានដើរតួក្នុងការធ្លាក់ចុះនៃទេសចរណ៍ចិន។ លោកបានមានប្រសាសន៍ថា "អ្វីៗមិនកើតឡើងនៅក្នុងប្រទេសថៃទេ ប៉ុន្តែប្រទេសថៃគឺជាគោលដៅនៃការវាយប្រហារ"។ ពាក្យចចាមអារ៉ាមបានកើតមានជាបន្តបន្ទាប់រហូតមកដល់ដើមឆ្នាំនេះ ស្ថានទូតថៃនៅទីក្រុងប៉េកាំងបានចេញសេចក្តីថ្លែងការណ៍ធានាចំពោះភ្ញៀវទេសចរថា មន្ត្រីនឹងចាត់វិធានការដើម្បីធានាសុវត្ថិភាពភ្ញៀវទេសចរ។ ដោយឡែកប្រធានសមាគមភ្នាក់ងារទេសចរណ៍កម្ពុជា លោកស្រី ឆាយ ស៊ីវលីន ប្រាប់ AFP ថា ស្ថានការណ៍កាន់តែមិនសូវល្អក្រោយផ្ទុះរឿងភាពយន្តនេះ។ លោកស្រីបាននិយាយថា ក្រុមហ៊ុនរបស់លោកស្រីមិនទាន់ទទួលបានក្រុមទេសចរណ៍ចិនទេរហូតមកដល់ពេលនេះ ហើយមតិរិះគន់បានបង្ហាញពីការព្រួយបារម្ភរបស់អ្នកទេសចរជាច្រើនអំពីសុវត្ថិភាព។ លោកស្រីបានមានប្រសាសន៍ថា "ប្រសិនបើរដ្ឋាភិបាលចិនជួយ យើងនឹងទទួលភ្ញៀវទេសចរក្នុងពេលឆាប់ៗនេះ ព្រោះប្រជាជនចិនស្តាប់តាមរដ្ឋាភិបាលរបស់ពួកគេ"[12]។

បើតាមគេហទំព័រ Saby News ចេញផ្សាយថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ បានសរសេរអំពីការលើកឡើងរបស់ស្ថានទូតជប៉ុនថា រឿង"No More Bets" មិនប៉ះពាល់ខ្លាំងដល់ទេសចរទេ តែ កម្ពុជាត្រូវកែលម្អចំណុចខ្លះដើម្បីវិស័យទេសចរ។ និយាយតែចំពោះភ្ញៀវទេសចរជប៉ុន ឯអគ្គរដ្ឋទូតជប៉ុន

---

[10] https://www.thestar.com.my/aseanplus/aseanplus-news/2023/08/29/haven-for-scams-hit-movies-further-sour-chinese-view-of-south-east-asia

[11] https://www.lifestyleasia.com/bk/entertainment/movies/no-more-bets-scaring-chinese-tourists-from-thailand/

[12] https://www.lifestyleasia.com/bk/entertainment/movies/no-more-bets-scaring-chinese-tourists-from-thailand/

ប្រចាំនៅកម្ពុជា លោក UENO ATSUSHI ថា ការចាក់បញ្ចាំខ្សែភាពយន្តរឿង "សូមបញ្ឈប់ការភ្នាល់បន្តទៀត" ឬ No More Bets របស់ចិនដែលធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍ភ្ញៀវទេសចរចិន និងបណ្ដាប្រទេសមួយចំនួនដែលមានបំណងមកលេងកម្ពុជាឱ្យមានការភ័យខ្លាចដោយសារឧក្រិដ្ឋកម្មជួញដូរមនុស្សនោះ គឺភ្ញៀវទេសចរជប៉ុនពុំមានអារម្មណ៍បែបនេះឡើយ ហើយម្យ៉ាងរឿងបែបនេះ មិនត្រូវបានអនុញ្ញាតឱ្យចាក់បញ្ចាំង ឬចែករំលែកទូលំទូលាយឡើយនៅជប៉ុនឡើយ។

នៅគ្រាដែលប្រទេសជិតខាងកម្ពុជា កំពុងស្រូបយកភ្ញៀវទេសចរអន្តរជាតិ សម្រាប់កម្ពុជាត្រូវបានគេមើលឃើញថាទាញបានចំនួនភ្ញៀវទេសចរតិចជាងគេ ជាពិសេសបើប្រៀបធៀបនឹងប្រទេសវៀតណាម និងថៃ។ តាមរយៈវេទិការតុមូលរវាងអ្នកសារព័ត៌មានកម្ពុជា ជាមួយឯកអគ្គរដ្ឋទូតជប៉ុនដែលរៀបចំដោយក្លឹបអ្នកកាសែតកម្ពុជានៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ នេះ លោក UENO ATSUSHI បានផ្ដល់អនុសាសន៍ថា ដើម្បីកំណើនភ្ញៀវទេសចរ កម្ពុជាត្រូវកែលម្អរចំណុចខ្វះខាតខ្វះទៀត និងអនុវត្តឱ្យមានលទ្ធផលជាក់ស្ដែង។ លោក UENO ATSUSHI ៖ "យើងចូលរួមអបអរសាទរជាមួយប្រជាជនកម្ពុជា ដែលប្រាសាទកោះកេរ ត្រូវបានដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក ធ្វើឱ្យពិភពលោកសម្លឹងមើលគោលដៅទេសចរមកកាន់កាន់កម្ពុជាកាន់តែច្រើន ទន្ទឹមនឹង កម្ពុជាក៏មានធនធានទេសចរណ៍ជាច្រើនដែរ។ ប៉ុន្តែអ្វីដែលយើងត្រូវកែលម្អនោះ គឺប្រព័ន្ធធ្វើដំណើរ សេវាស្នាក់នៅ និងហូបចុកនៅកន្លែងកម្សាន្តផ្ទាល់នោះតែម្ដង គឺថាយើងមិនទាន់បំពេញបានល្អទេ"។ ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំនៅកម្ពុជារូបនេះរំលឹកថា រូបលោកផ្ទាល់ធ្លាប់ទៅទស្សនាប្រាសាទព្រះវិហារដោយប្រើពេលវេលា និងលុយច្រើន សម្រាប់ការទៅទស្សនាមួយជើង ព្រោះនៅក្បែរនោះពុំមានសណ្ឋាគារ ភោជនីយដ្ឋាន ព្រមទាំងសេវាកម្មផ្សេងៗសមរម្យសម្រាប់ភ្ញៀវទេសចរទូទៅ។ លោកថាពេលលោកទៅទស្សនាប្រាសាទនោះ គឺដំណើរផ្លូវវែងឆ្ងាយ ហើយត្រូវត្រឡប់មកទីប្រជុំជននៅក្រុងសៀមរាប ឬភ្នំពេញវិញទាំងកណ្ដាលយប់។ ក្រៅពីនេះលោកថា អាជ្ញាធរអាចមើលលើកត្តា សន្តិសុខ និងសេវាកម្មបន្ទាប់បន្សំខ្វះទៀត។ ទោះជាយ៉ាងណា ប្រធានក្លឹបអ្នកកាសែតកម្ពុជា លោក ពុយ គា បើទោះបីជាមិនអាចជម្រះមន្ទិលរបស់មហាជនបាន ១០០% លើបញ្ហាវិស័យទេសចរនេះ តែក៏ជាការបញ្ជាក់ដ៏សំខាន់មួយរបស់ប្រទេសជប៉ុនតាមរយៈឯកឧត្តម UENO ATSUSHI ក្នុងការចូលរួមចំណែកចែករំលែកបទពិសោធន៍ និងការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា។

រាល់ការលើកឡើងខាងលើជាការបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំងសម្រាប់ប្រទេសថៃ មីយ៉ាន់ម៉ា និងប្រទេសកម្ពុជាលើវិស័យទេសចរណ៍។ ស្របពេលដែលវិស័យទេសចរណ៍នៅទ្រឹងមិនមានសន្ទុះទៅមុខ និងមិនសូវមានភ្ញៀវទេសចរចិនមកដំណើរកម្សាន្ត បណ្តាក្រសួងមន្ទីរពាក់ព័ន្ធ ក៏ដូចជាមហាជនខ្មែរក៏មានការព្រួយបារម្ភខ្លាំងដោយខ្សែភាពយន្តចិន «No More Bets» ដែលកំពុងចាក់ផ្សាយនៅក្រៅប្រទេស កំពុងរងប្រតិកម្មដ៏សម្បើមពីបណ្តាពលរដ្ឋកម្ពុជាផ្ទុះឡើងដោយសារភាពយន្តខាងលើ មានតួអង្គក្នុងសាច់រឿង ពាក់អាវដែលមានសរសេរអក្សរខ្មែរ និងបានប្រព្រឹត្តបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ ។ ជុំវិញរឿងនេះធ្វើឱ្យសាធារណជនក៏ដូចជាមន្ត្រីពាក់ព័ន្ធលើកឡើងនូវទស្សនៈក៏ដូចជាការព្រួយបារម្ភ និងស្នើឱ្យមានវិធានការផ្សេងៗផងដែរ។ លោក ស៊ុំ ម៉ាប់ អ្នកនាំពាក្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានលើកឡើងថា រដ្ឋាភិបាលកម្ពុជាបានពិភាក្សាជាមួយស្ថានទូតចិននៅទីក្រុងភ្នំពេញ ហើយបានស្នើសុំឱ្យបញ្ឈប់ការចាក់បញ្ចាំង No More Bets នៅក្នុងប្រទេសចិន។ "យើងនឹងមានចម្លើយនៅប៉ុន្មានថ្ងៃខាងមុខអំពីបញ្ហានេះ។ យើងសូមអរគុណប្រជាជនរបស់យើងដែលបានយកចិត្តទុកដាក់ចំពោះសេចក្តីថ្លៃថ្នូររបស់ប្រទេសយើង»។ ក្នុងកិច្ចសម្ភាសន៍ជាមួយប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក លោកបាននិយាយថា ក្រសួងបានមើលឃើញ ហើយឥឡូវនេះយល់ថា ភាពយន្តនេះមានឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់កម្ពុជា។ រដ្ឋាភិបាលកម្ពុជាមិនអាចបញ្ឈប់ការចាក់បញ្ចាំងភាពយន្តនេះបានទេ ព្រោះវាផលិតនៅប្រទេស ចិន។ ទោះជាយ៉ាងនេះក្តី ក្រសួងបានណែនាំដល់គ្រប់ភាគីពាក់ព័ន្ធនៅទូទាំងប្រទេស ជៀសវាងការបញ្ចាំងភាពយន្តនេះនៅក្នុងរោងកុនកម្ពុជា ដោយសារខ្លឹមសារអវិជ្ជមានដែលយកមកបង្ហាញ[13]។ ទោះយ៉ាងណា អ្នកនាំពាក្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បដិសេធថា ភាពយន្តឧក្រិដ្ឋកម្មជួញដូរមនុស្សនេះមិនបានឆ្លុះបញ្ចាំងពីការពិតនៅកម្ពុជាឡើយ «គឺមិនមែនជាទីកន្លែងដែលមានអំពើចឹងៗទេ ហើយអ្វីដែលគាត់ចេញមកហ្នឹងតិច-ច្រើនគ្រាន់តែអក្សរខ្មែរដែលប្រើផ្តេសផ្តាសនៅលើអាវហ្នឹងវាប៉ះពាល់រួចទៅហើយ»។ ចំណែកលោក តុប សុកក្រ អ្នកនាំពាក្យក្រសួងទេសចរណ៍ បានឱ្យដឹងថាក្រសួងពាក់ព័ន្ធកំពុងធ្វើការអន្តរាគមន៍លើករណីនេះ ដោយការប្តេជ្ញាចិត្ត «យើងនឹងខិតខំធ្វើនូវអ្វីដែលជាការបន្សាបនូវឥទ្ធិពលដែលគេនិយាយមិនល្អពីកម្ពុជារបស់យើង ហើយយើងនឹងប្រែក្លាយពីចំណុចអវិជ្ជមានឱ្យជាអ្វីដែលអាចទាក់ទាញវិញ»។ យ៉ាងណាចំពោះករណីនេះកម្ពុជាមិនទាន់បានសហការ

---

[13] https://www.khmertimeskh.com/501367822/cambodia-wants-chinese-movie-no-more-bets-taken-off-screens/

ជាមួយភាគីថៃនិងមីយ៉ាន់ម៉ា ដើម្បីឆ្លើយតបចំពោះភាពយន្តចិននេះឡើយ ប៉ុន្តែក្រសួងកំពុងព្យាយាមហាមឃាត់ក្នុងការផ្សព្វផ្សាយភាពយន្តនេះនៅតាមបណ្តាញសង្គមក្នុងប្រទេសកម្ពុជា ខណៈកម្ពុជាបានដាក់សំណើរដល់ស្ថានទូតចិនឱ្យជួយដោះស្រាយផងដែរ។ នេះបើតាមការបញ្ជាក់ពីលោក ស៊ុំ ម៉ាប់ រដ្ឋលេខាធិការក្រសួងវប្បធម៌[14]៕

បន្ថែមពីលើប្រតិកម្មរបស់សាធារណជននៅពេលផ្តល់បទសម្ភាសន៍ជាមួយវិទ្យុបារាំង RFI លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បញ្ជាក់ថា កម្ពុជាទទួលយកមិនបានឡើយចំពោះខ្សែភាពយន្តចិន «No More Bets» នេះ។ តែទោះជាយ៉ាងនេះក្តី ក៏កម្ពុជាមិនអាចធ្វើអ្វីបាន ដ្បិតថាខ្សែភាពយន្តនេះបានចាក់បញ្ចាំងរួចទៅហើយ[15]។

ចំពោះរឿងនេះដែរ ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ លើកឡើងថា នោះជាការលាបពណ៌ចំពោះករណីចោទកម្ពុជាជាជម្រកនៃហ្គេមអនឡាញខុសច្បាប់។ នេះបើតាមលោកបណ្ឌិត ទូច សុឃៈ អ្នកនាំពាក្យរងក្រសួងមហាផ្ទៃដែលបានថ្លែងប្រាប់សារព័ត៌មានកោះសន្តិភាពនាថ្ងៃទី២៦ ខែកញ្ញា នេះ។ អ្នកនាំពាក្យរងក្រសួងមហាផ្ទៃបានបន្តថា ការដែលលាបពណ៌កម្ពុជាថា ជាជម្រកនៃហ្គេមអនឡាញខុសច្បាប់ អាចជាចេតនាមិនល្អ ពោលគឺអាចជាការកេងចំណេញផ្នែកនយោបាយ និងអាចជា សមរភូមិទេសចរណ៍ដែលបណ្តាប្រទេសក្នុងតំបន់និងពិភពលោក កំពុងដណ្តើមទីផ្សារ។ ម្យ៉ាងទៀត យើងដឹងទាំងអស់គ្នាហើយថា និន្នាការពិភពលោកបច្ចុប្បន្ន គឺកំពុងរីកសាយភាពយ៉ាងគំហុកលើ វិស័យបច្ចេកវិទ្យា ដែលបណ្តាប្រទេសភាគច្រើនតែងប្រឈមនឹងបញ្ហាអវិជ្ជមានតាមអនឡាញ គ្រាន់តែថា តិចឬច្រើនប៉ុណ្ណោះ។ ដូច្នេះ កុំព្យាយាមទម្លាក់បន្ទុកនេះលើកម្ពុជា។ អ្នកនាំពាក្យរងក្រសួងមហាផ្ទៃបានបន្តទៀតថា ក្នុងនោះបើបរទេសមិនការពារយើង យើងជាខ្មែរគប្បីទុកនិន្នាការមួយឡែករួមគ្នាបង្ហាញភាពស្អាតស្អំរបស់កម្ពុជាយើង ទៅកាន់មតិអន្តរជាតិកុំឱ្យគិតអវិជ្ជមានលើកម្ពុជា។ យើងនៅចាំទេ កាលពីប៉ុន្មានឆ្នាំមុន នៅពេលក្តាប់ព័ត៌មានបានថា មានករណីកើតមានបញ្ហាអវិជ្ជមានតាមអនឡាញ សម្តេចតេជោ អតីតនាយករដ្ឋមន្ត្រី បានចាត់វិធានការក្តៅគគុកប្រកបដោយប្រសិទ្ធភាព។

---

[14] https://wmc.org.kh/article/109329/ministry-of-culture-rejects-chinese-film-no-more-bets-as-not-reflecting-cambodias-situation/

[15] https://www.rfi.fr/km

អ្នកនាំពាក្យរង់ក្រសួងមហាផ្ទៃបានបន្តថា ថ្មីៗនេះដែរ មានផែនការទាញទម្លាក់កម្ពុជាចូលទៅក្នុងបញ្ជីមិនសូវល្អមួយនៃការជួញដូរមនុស្សតាមគ្រប់រូបភាព សម្តេចក្រឡាហោម ស ខេង អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏បានចាត់គ្រប់មធ្យោបាយ រហូតគេដកកម្ពុជាចេញពីបញ្ជីអវិជ្ជមាននោះវិញ។ អ៊ីចឹងហើយ បើគេព្យាយាមទម្លាក់យើងចូលកក់ យើងគប្បីរួមគ្នាទាញឡើងមកវិញ ពោលគឺយើងជឿជាក់លើកម្ពុជា។ ក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី លោករិះរកគ្រប់យុទ្ធសាស្ត្រលើការគ្រប់គ្រងសន្តិសុខជារួមក្នុងនោះឯកឧត្តម បានចាត់បញ្ជូនអគ្គស្នងការរងម្នាក់ ធ្វើជាស្នងការនគរបាលខេត្តព្រះសីហនុ គឺលោកឧត្តមសេនីយ៍ឯក ស រដ្ឋា ដែលបានទទួលការបណ្តុះបណ្តាលជំនាញនគរបាលពីក្រៅប្រទេសនិងមានបទពិសោធន៍លើជំនាញសន្តិសុខ ប្រឆាំងភេរវកម្ម អន្តោប្រវេសន៍ជាដើម និងចាត់អគ្គស្នងការរងម្នាក់ទៀត ជាស្នងការនគរបាលរាជធានីភ្នំពេញ គឺលោកឧត្តមសេនីយ៍ទោ ជួន ណារិន ដែលមហាជនដឹងថា លោកមានជំនាញខាងព្រហ្មទណ្ឌ និងការងារសន្តិសុខ។ ក្រៅពីនេះ ក្នុងក្របខណ្ឌរាជរដ្ឋាភិបាល សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី បានចាត់តាំងឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី ទទួលកិច្ចការសន្តិសុខ និងជាប្រធានអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលលោកមានជំនាញ និងបទពិសោធន៍ពេញលេញ ព្រោះអតីតជាអគ្គស្នងការនគរបាលជាតិ។ ទាំងនេះបញ្ជាក់ថា កម្ពុជាមិនមែនជាប្រទេសទទួលហ្គេមអនឡាញខុសច្បាប់ ឬឧក្រិដ្ឋជននោះទេ។

ករណីចំណាត់ការលើភាពយន្តចិនដែលមានអក្សរខ្មែរនោះ លោកបណ្ឌិត ទូច សុឃៈ បានបញ្ជាក់ថា យើងគាំទ្រក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទាំងចំណាត់ការនិងទស្សនៈ ដែលចាត់ទុកថាមានអក្សរខ្មែរក្នុងភាពយន្តនេះ នាំឱ្យមានការភាន់ច្រឡំថា ឈុតឆាកឧក្រិដ្ឋកម្មទាំងនោះកើតឡើងនៅកម្ពុជា ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស កេរ្តិ៍ឈ្មោះ ជះផលអវិជ្ជមានដល់វិស័យទេសចរណ៍ វិនិយោគជាដើម។ យើងជឿជាក់លើអ្វីដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកំពុងធ្វើថា នឹងទទួលលទ្ធផលជាវិជ្ជមាន។

ចំពោះភាពល្បីល្បាញនៃរឿងនេះ ធ្វើឱ្យមានភាពចម្រូងចម្រាស់ជាច្រើនដោយអ្នកខ្លះមានការគាំទ្រនិងអ្នកខ្លះធ្វើការប្រឆាំងយ៉ាងដាច់អហង្ការដែលធ្វើឱ្យមានការប៉ះពាល់ដល់កិត្តិនាម សេចក្តី

ថ្ងៃថ្នូររបស់ប្រជាតិខ្លួនជាពិសេសនៅកម្ពុជាតែម្តង ដែលអ្នកខ្លះយល់ថាជាការប៉ះពាល់ដល់វិស័យទេសចរណ៍នៅកម្ពុជា។ នៅក្នុងការបញ្ចេញមតិយោបល់នៅតាមបណ្តាញសង្គមអ្នកខ្លះលើកឡើងថា No More Bats ជារឿងល្អមើល ទាក់ទាញ ផ្តល់ការអប់រំ ធ្វើឱ្យមានការបង្កើនការប្រុងប្រយ័ត្ន ហើយអ្នកខ្លះក៏មានអារម្មណ៍ភ័យខ្លាចនៅពេលមើលរឿងនេះ និងមានការផ្តល់យោបល់ថាជារឿងដែលធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់ប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ី។ "នេះជាភាពយន្តល្អមើលណាស់ ដើម្បីបង្ហាញពិភពលោកថាមនុស្សអាក្រក់ទាំងនេះអាចធ្វើទៅរួចដើម្បីចាប់ជនរងគ្រោះស្លូតត្រង់ (ម៉ាឡេស៊ី តៃវ៉ាន់ ចិន សិង្ហបុរី ជាដើម) ហើយធ្វើទារុណកម្មពួកគេទៅឋាននរកនៅក្នុងបរិវេណ KK ដែលគេការពារដោយអាវុធយ៉ាងតឹងរ៉ឹងរហូតដល់ពួកគេត្រូវគោរពច្បាប់ហ្គេមដើម្បីទាក់ទាញ និងបោកប្រាស់លុយដែលរកបានដោយលំបាករបស់មនុស្ស! នេះជារឿងពិតដែលកើតឡើងនៅអាស៊ី (ភូមា ថៃ ឡាវ កម្ពុជា) ជនរងគ្រោះក្រីក្រត្រូវបានចាប់ខ្លួន ធ្វើទារុណកម្ម និងសរីរាង្គមនុស្សត្រូវយកចេញពីសាកសពទៅលក់ឱ្យអ្នកមាន! ឮតាមវីដេអូថា សាកសពត្រូវបានគេបោះចោលក្នុងសមុទ្របើកចំហ(ទឹកដោយចេតនា)។" "យោងតាមអង្គការសហប្រជាជាតិ អេហ្ស៊ីបគឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលរងផលប៉ះពាល់ខ្លាំងជាងគេលើពិភពលោកដោយការជួញដូរសរីរាង្គបន្ទាប់ពីប្រទេសចិន ហ្វីលីពីន និងឥណ្ឌា។" "លឺថារឿងនេះថតនៅប្រទេសថៃ ហើយចាក់បញ្ចាំងនៅស្រុកខ្មែរ! វាមិនយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា។ ជនបរទេសអាក្រក់ខ្លះធ្វើអាក្រក់នៅស្រុកខ្មែរ ឯប្រទេសខ្លះទៀតសុទ្ធតែមកស្រុកខ្មែរ! អ្វីៗមិនមែនខ្មែរធ្វើទេ!" "ខ្ញុំឃើញអក្សរ(ខ្មែរ)ក្នុងរឿងនេះ វាពាក់ព័ន្ធជាមួយកម្ពុជា ប៉ុន្តែកម្ពុជាមិនចូលចិត្តរឿងនេះទេ កម្ពុជាតែងតែមានសន្តិភាព។ ខ្ញុំមិនគាំទ្ររឿងនេះទាល់តែសោះ កម្ពុជាមិនមែនជាការបោកប្រាស់ទេ។ ជារៀងរាល់ឆ្នាំតែងតែមានភ្ញៀវទេសចរណ៍មកលេងកម្ពុជាច្រើនណាស់(ប្រាសាទអង្គរវត្ត) ប្រទេសកម្ពុជាជាប្រទេសដែលមានវប្បធម៌ដ៏ស្រស់បំព្រង និងជាប្រទេសដ៏ស្រស់ស្អាត មនុស្សជាច្រើននៅក្នុងប្រទេសកម្ពុជាពិតជារួសរាយរាក់ទាក់ និងគួរសម។ ខ្ញុំស្រលាញ់ប្រទេសកម្ពុជា។" "គ្រាន់តែគេនិយាយអីប៉ះខ្មែរតិចអត់បានមែន? ហើយមើលផងថាល្បែងស៊ីសង ការជួញដូរមនុស្សមានមែនអត់? ឬដឹងហើយធ្វើមិនដឹង? នេះគ្រាន់តែគេធ្វើជារឿងសោះ យើងគួរទុកវាជាការចែករំលែក ហើយបើកចិត្តតិចទៅ។ គ្មានបរទេសណាមើលរឿងហ្នឹងហើយខ្លាចប្រទេសខ្មែរទេ មានតែខ្មែរទេខ្លាចតែគេមើលមកអាក្រក់។" " បើចង់ប្រើភាសាខ្មែរ ម៉េចមិនសុំខ្មែរសរសេរឱ្យ? ប្រជាជនកម្ពុជាមិនសប្បាយចិត្តទេពេលប្រើពុម្ពអក្សរខុស។ ពួកគេមិនអាចអានបានទេ។ មិនគោរពជាតិ និងភាសារបស់ខ្ញុំ" "វាជារឿងពិតរបស់ប្រជាពលរដ្ឋខ្មែរ ហើយកម្ពុជាជាប្រទេសគ្រោះ

ថ្នាក់។" "ឧក្រិដ្ឋកម្មដែលកំពុងកើតឡើងនៅភាគខាងជើងប្រទេសមីយ៉ាន់ម៉ា មិនត្រូវបានប្រព្រឹត្ត ដោយប្រជាជនមីយ៉ាន់ម៉ាទេ។ ប្រជាជនភូមាគឺជាជនរងគ្រោះតែមួយគត់។ ទោះបីវាកំពុងកើតឡើង ក្នុងទឹកដីមីយ៉ាន់ម៉ាក៏ដោយ អ្នកដែលដឹកនាំសកម្មភាពឧក្រិដ្ឋកម្មទាំងនេះ គឺជាជនជាតិចិនបរទេស។" " នេះជាភាពយន្តឯកសារដ៏ល្អមួយសម្រាប់មើល ហើយត្រូវប្រយ័ត្នចំពោះអ្វីដែលអ្នកអាចទទួលបាន។ ឧក្រិដ្ឋកម្មខ្លួនឯងគឺប្រព្រឹត្តឡើងដោយបុរសជនជាតិចិនដែលល្បួងប្រជាជនរបស់ពួកគេពីប្រទេសចិនមកកម្ពុជា និងមីយ៉ាន់ម៉ា ដោយមិនគិតពីប្រទេសជាច្រើនទៀតដែលមិនបានរៀបរាប់នៅក្នុងភាពយន្ត។" "វិនិយោគិនចិនគឺជាគន្លឹះនៃភាពជោគជ័យផ្នែកសេដ្ឋកិច្ចនៅកម្ពុជា។ ប៉ុន្តែក្នុងពេលជាមួយគ្នានេះ ក្នុងចំណោមពួកគេគឺជាឧក្រិដ្ឋជនដែលនាំឱ្យយើងមានបញ្ហា និងអាម៉ាស់មកលើរដ្ឋាភិបាលរបស់យើង។ ឧក្រិដ្ឋជនទាំងនោះភាគច្រើនជាគោលដៅពាណិជ្ជកចិនភ្ញៀវទេសចរ និងទោះបីជាជនជាតិចិនសាមញ្ញក៏ដោយ។😢 យើងចាប់ផ្តើមពួករណីភ័យខ្លាចជាច្រើនដូចជាក្នុងរឿងហូលីវូដ ឬភាពយន្តចិនជាដើម..😢.។" " ឧក្រិដ្ឋកម្មដែលមនុស្សទាំងនោះប្រព្រឹត្តនៅក្នុងភាពយន្តទាំងនេះមិនមានមូលដ្ឋាននៅប្រទេសកម្ពុជាទេ។ យ៉ាងហោចណាស់អ្នកនិពន្ធគួរតែព្រមានជាមុន។ ខកចិត្ត" "វាត្រឹមត្រូវដែលធ្វើនៅភូមា ប៉ុន្តែអ្នកមានដែលធ្វើគឺចិន។ ពលរដ្ឋមីយ៉ាន់ម៉ាជាច្រើននាក់ ស្ថិតក្នុងចំណោមជនរងគ្រោះ។ អ្នករស់នៅទីនោះនិយាយថា ថៅកែជាជនជាតិចិន។ សូមបញ្ឈប់រឿងជនជាតិចិនស្អប់មីយ៉ាន់ម៉ា។"

រួមសេចក្តីមក បញ្ហាឧក្រិដ្ឋកម្មល្បែងអនឡាញនេះមិនមែនគ្រាន់តែជាក្តីបារម្ភសម្រាប់តែ កម្ពុជាទេ តែវាក៏ជាក្តីបារម្ភរបស់បណ្តាប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ផងដែរ។ ជាធម្មតារឿងដែលថតជាភាពយន្តគឺជាកញ្ចក់ឆ្លុះបញ្ចាំងតថភាពសង្គមដែលមានលំនាំតាមការពិតដោយមានការច្នៃប្រឌិតបន្ថែមបន្ថយរបស់អ្នកនិពន្ធ ពេលខ្លះក៏អាចខ្វះឬហួសពីការពិតខ្លះដែរ។ អ្នកទស្សនាអាចមានអារម្មណ៍រំភើប ភ័យ ព្រួយ សប្បាយ តក់ស្លុត...ទៅតាមដំណើររឿងដែលជាការប៉ិនប្រសប់របស់អ្នកផលិត ប៉ុន្តែក៏មិនអាចចាត់ទុកថាជារឿងពិត១០០ភាគរយដែរ ហើយរឿងហេតុខ្លះគ្រាន់តែកើតឡើងក្នុងជ្រុងណាមួយនៃតំបន់មួយប៉ុណ្ណោះ មិនបានបញ្ជាក់ពីស្ថានភាពក្នុងប្រទេសទាំងមូលនោះទេ ហើយបើតាមរឿង No More Bets នេះឃើញថាព្រឹត្តិការណ៍មិនបានបញ្ជាក់នៅក្នុងប្រទេស កម្ពុជានោះទេ គ្រាន់តែមានសរសេរអក្សរខ្មែរនៅលើអាវក្រុមការងារនិងលើរថយន្តដែលបកប្រែមិនត្រឹមត្រូវនិងអានមិនកើតទៀតផង ប៉ុន្តែតិចឬច្រើនវាក៏បានជះឥទ្ធិពលមិនល្អមកលើប្រទេសកម្ពុជាផង

ដែរ ជាពិសេសកិត្តិយស សេចក្តីថ្លៃថ្នូរ និងវិស័យទេសចរណ៍ជាដើម។ បើទោះបីជាមតិមួយចំនួនបានគាំទ្រថា ភាពយន្តចិនពីររឿង គឺរឿង Lost in the Stars (ចិនៈ 消失的她) និងរឿង No More Bets (ចិនៈ 孤注一掷 ) បានពញ្ញាក់ស្មារតី និងអប់រំជនជាតិចិនឬក៏បរទេសណាក៏ដោយ កុំឱ្យលង់ជឿការផ្សព្វផ្សាយពីការឆោរបោកប្រាស់តាមអនឡាញ និងការលេងល្បែង ដែលអាចជាការរៀបចំដោយក្រុមឧក្រិដ្ឋជនចាប់ជំរិតទារប្រាក់ក៏ដោយ ក៏ប៉ុន្តែរឿងនេះបានទទួលការរិះគន់យ៉ាងព្រោងព្រាត និងធ្វើឱ្យប៉ះពាល់ខ្លាំងដល់អារម្មណ៍និងផលប្រយោជន៍របស់ប្រទេសដែលពាក់ព័ន្ធដែលមាន ថៃ មីយ៉ាន់ម៉ា និងកម្ពុជាជាដើម។ ក្នុងករណីនេះដែរយើងឃើញថា ខាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក៏បានសម្រេចចាត់វិធានការដោយបានដាក់លិខិតទៅប្រទេសចិន តាមរយៈស្ថានទូតចិនប្រចាំកម្ពុជា និងស្នើសុំកុំឱ្យចាក់បញ្ចាំងភាពយន្តចិនមួយនេះ។ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈស្នើឱ្យរដ្ឋាភិបាលចិនអន្តរាគមន៍បញ្ឈប់ការផ្សព្វផ្សាយខ្សែភាពយន្តចិន ក្រោមចំណងជើងថា «No More Bets» ទាក់ទងនឹងឧក្រិដ្ឋកម្មល្បែងអនឡាញ ដែលក្រសួងចាត់ទុកថាបានបន្ទាបតម្លៃកម្ពុជា។ យើងទទួលស្គាល់ទាំងស្រុងចំពោះមតិរិះគន់និងការប្រតិកម្មនានា ប៉ុន្តែអ្វីដែលយើងគួរបន្តយកចិត្តទុក ដាក់នោះគឺខិតខំរកវិធីសាស្ត្រកែលំអពង្រឹងវិស័យទេសចរណ៍ឡើងវិញដូចជាៈ

-ពង្រឹងសន្តិសុខជាតិឱ្យបានខ្លាំងក្លាឡើងវិញ ជាពិសេសតំបន់ដែលអាចកើតមាននូវការលេងល្បែងហ្គេមអនឡាញ ដែលមានជនជាតិចិនច្រើនបណ្តុំនៅទីនោះ។

-ស្នើសុំឱ្យស្ថានទូតចិនប្រចាំនៅកម្ពុជាជួយចេញសេចក្តីថ្លែងការណ៍ទៅកាន់ប្រជាជនចិនថា ប្រទេសកម្ពុជាជាប្រទេសដែលមានសុខសន្តិភាពសុវត្ថិភាពល្អ មិនមានហានិភ័យដូចក្នុងការសម្តែងរឿង No More Bets នោះទេ ។

-អភិវឌ្ឍប្រព័ន្ធធ្វើដំណើរឱ្យបានកាន់តែប្រសើរ សេវាស្នាក់នៅ និងអាហារដ្ឋាននៅកន្លែង កម្សាន្តផ្ទាល់តែម្តង ។

-អាជ្ញាធរពាក់ព័ន្ធអាចធ្វើសន្និសីទកាសែត ដោយបង្ហាញសកម្មភាពមួយចំនួនដែលបានបង្ក្រាបរាល់បទល្មើសល្បែងហ្គេមអនឡាញដែលមានកន្លងមករួចមកហើយទៅកាន់សាធារជនក្នុងស្រុកក៏ដូចផ្សព្វផ្សាយទៅកាន់ពិភពលោក និងបញ្ជាក់ថាបញ្ហានេះមិនមានទៀតទេនៅក្នុងប្រទេសកម្ពុជា ជាពិសេសខេត្តព្រះសីហនុ។

-ជៀសវាងចរាចរណ៍ចាក់រឿងទាំងពីរហ្នឹងនៅក្នុងផ្ទៃប្រទេសរបស់យើង ដោយមិនឱ្យបញ្ចាំងតាមរោង និងផ្សព្វផ្សាយតាមបណ្ដាញផ្សព្វផ្សាយសង្គមផ្សេងៗ ហើយមហាជនក៏កុំចូលរួមមើលឡាយ និង ស៊ែរ...ដែលធ្វើឱ្យរឿងទាំងនោះកាន់តែល្បី។

- រាជរដ្ឋាភិបាលក៏ដូចជាអាជ្ញាធរពាក់ព័ន្ធជំរុញនូវការពង្រឹងការអនុវត្តច្បាប់ឱ្យបានខ្លាំងក្លា និងលុបបំបាត់អំពើពុករលួយផ្សេងៗក្នុងគ្រប់រូបភាព។ យើងគួរពិនិត្យឡើងវិញអំពីប្រព័ន្ធ ឬអំពើពុករលួយនៅក្នុងសង្គមរបស់ខ្លួនឯង ចោរកម្ម ឧក្រិដ្ឋកម្មផ្សេងៗ ដែលអាចប្រព្រឹត្តនៅកម្ពុជាបាន។

-បង្កើតព្រឹត្តិការណ៍ថ្មីៗក្នុងឱកាសពិសេសៗនៃពិធីបុណ្យជាតិមួយចំនួនដោយពង្រីកការផ្សព្វផ្សាយពីសុខសន្តិភាព ភាពរីកចម្រើន និងភាពស្រស់បំព្រងនៃប្រជាជនទៅកាន់ពិភពលោកឱ្យបានទូលំទូលាយ។

-បន្ធូរបន្ថយការរឹតបន្តឹងទិដ្ឋាការសម្រាប់ជនជាតិចិនក៏ដូចជាជនជាតិបរទេសផ្សេងៗ។